ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

# ស្តីពី

# គ្រូបង្រៀន

បានទទួលការឯកភាព

ពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា

ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

# បុព្វកថា

វិស័យអប់រំជាកត្តាគន្លឹះមួយក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ដើម្បីធានានិរន្តរភាពក្នុងការអភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញ សំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ គោលការណ៍ឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លើយតបនឹងបរិបទខាងលើ និងបរិបទសកលភាវូបនីយកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀនក្នុងគោលបំណងកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងមានការទទួលស្គាល់ពីសង្គម។

គោលនយោបាយស្តីពីគ្រូបង្រៀន នឹងធានាឱ្យគ្រូបង្រៀនមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈតាមរយៈការបណ្តុះបណ្តាលមុនពេលបំពេញការងារនិងក្នុងពេលបំពេញការងារ។ គោលនយោបាយនេះបានបង្ហាញពីយុទ្ធសាស្ត្រសំខាន់ៗសម្រាប់យកទៅអនុវត្តសំដៅសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះដៃគូអភិវឌ្ឍទាំងអស់ ដែលបានជួយគាំទ្រទាំងស្មារតីនិងសម្ភារៈ ដើម្បីធ្វើឱ្យសម្រេចគោលនយោបាយស្តីពីគ្រូបង្រៀនសម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍគ្រូបង្រៀន។

ក្រសួងសង្ឃឹមថា ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ផ្នែកឯកជន សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនឱ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម_សិទ្ធី**

## មាតិកា


**១. សេចក្ដីផ្ដើម**................................................................................................................................ ១

**២. ចក្ខុវិស័យ** ................................................................................................................................ ២

**៣. គោលបំណង**................................................................................................................................ ២

**៤. គោលដៅ**................................................................................................................................ ២

**៥. យុទ្ធសាស្ត្រ**................................................................................................................................ ២

៥.១ កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ................................................................ ២

៥.២ ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន................................................ ២

៥.៣ កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន ................................................................ ២

៥.៤ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ................................................................ ៣

៥.៥ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា........... ៣

៥.៦ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ ................................ ៣

៥.៧ លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន................................................................ ៣

៥.៨ ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន................................................................ ៣

៥.៩ ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន ................................ ៤

**៦. ផែនការសកម្មភាព** ................................................................................................ ៤

៦.១ ការបង្កើតយន្តការ ................................................................................................ ៤

៦.២ ការបង្កើតក្របខណ្ឌគតិយុត្ត................................................................................ ៤

៦.៣ ការគាំទ្រហិរញ្ញវត្ថុ ................................................................................................ ៥

៦.៤ ការបណ្តុះបណ្តាលធនធានមនុស្ស ................................................................ ៥

៦.៥ ដំណើរការអនុវត្តគម្រោង ................................................................................ ៥

**៧. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**................................................................ ៦

**៨. សេចក្ដីសន្និដ្ឋាន** ................................................................................................ ៧

**៩. សន្ធានុក្រម**................................................................................................................ ៨

# ១. សេចក្តីផ្តើម

ការរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការស្វែងរកឧត្តមភាពនៅលើពិភពលោក បានជំរុញឱ្យប្រទេសនីមួយៗខិតខំធ្វើការប្រកួតប្រជែងផលិតផល និងសេវាកម្មរបស់ខ្លួន។ ធនធានមនុស្សជាកម្លាំងចលករក្នុងការសម្រេចបំណងប្រាថ្នានេះ។ គ្រូបង្រៀនត្រូវបានគេទទួលស្គាល់និងឱ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក។ ការទទួលស្គាល់នេះបានស្តែងចេញតាមរយៈការប្រារព្ធទិវាគ្រូបង្រៀនជារៀងរាល់ឆ្នាំ។ ចំណេះដឹង ជំនាញ សីលធម៌ និងលក្ខណសម្បត្តិដែលជាតម្រូវការចាំបាច់សម្រាប់គ្រូបង្រៀនមានការប្រែប្រួលទៅតាមតម្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចវប្បធម៌ បច្ចេកវិទ្យានៃសង្គមពុទ្ធិ។

សហគមន៍អាស៊ានមានបំណងបង្កើនជីវភាព និងសុខុមាលភាពប្រជាជនតាមរយៈសកម្មភាពជាច្រើនដូចជា ការលើកកម្ពស់ការវិនិយោគវិស័យអប់រំ ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាពេញមួយជីវិត ការអនុវត្តវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងគ្រប់សកម្មភាពអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ប្រការនេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រូបង្រៀន។ ការសិក្សាក្នុងតំបន់ដោយប្រព័ន្ធវាយតម្លៃនិងវាស់វែងលទ្ធផលអប់រំ បានកំណត់គោលដៅក្នុងការអភិវឌ្ឍគោលនយោបាយគ្រូបង្រៀនដូចជា ការទាក់ទាញបេក្ខជនដែលមានសមត្ថភាពឱ្យចូលប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព ការគាំទ្រនិងលើកទឹកចិត្ត និងការទទួលបានការដឹកនាំល្អ។

រាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំដែលមានចែងក្នុងមុំទី១នៃយុទ្ធសាស្ត្រចតុកោណ។ ច្បាប់ស្តីពីការអប់រំមានគោលបំណងអភិវឌ្ឍធនធានមនុស្ស លើកកម្ពស់គុណភាពអប់រំ កំណត់សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលិកអប់រំដូចជា សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈ សិទ្ធិចូលរួមអភិវឌ្ឍស្តង់ដារអប់រំ សិទ្ធិទទួលសេវាអប់រំផ្សេងៗ ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងការបំពេញកាតព្វកិច្ចផ្សេងទៀត។ ប្រការនេះរួមចំណែកបំពេញសេចក្តីត្រូវការរបស់គ្រូបង្រៀននិងអ្នកសិក្សាឱ្យទទួលបាននូវចំណេះដឹងជំនាញ សីលធម៌ និងមានលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយគុណភាព។

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនរួមមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ និងគោលនយោបាយផ្សេងៗទៀត។ ដើម្បីឆ្លើយតបនឹងបរិបទនេះ ក្រសួងបានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀន ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យមានបុគ្គលិកលក្ខណៈពេញលេញ។

គោលនយោបាយស្តីពីគ្រូបង្រៀនមានវិសាលភាពលើការអប់រំសាធារណៈនិងឯកជនចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិនិងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

## ២. ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម។

## ៣. គោលបំណង

គោលនយោបាយស្តីពីគ្រូបង្រៀនមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ។

## ៤. គោលដៅ

៤.១ ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន។

៤.២ ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន។

៤.៣ ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ។

៤.៤ ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

## ៥. យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលបំណងនិងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោមៈ

### ៥.១ កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ

- ពិនិត្យឡើងវិញ កែលម្អ និងកសាងលិខិតបទដ្ឋានគតិយុត្ត
- កសាងយន្តការចាំបាច់សម្រាប់ផ្សព្វផ្សាយ អនុវត្ត គាំទ្រ ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ
- កសាងផែនការសកម្មភាពជាក់លាក់ និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ។

### ៥.២ ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន

- លើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម
- លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន
- កំណត់លក្ខណវិនិច្ឆ័យនិងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស
- ធ្វើទំនើបកម្មស្តង់ដារកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិនិងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក។

### ៥.៣ កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
- បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ
- កំណត់កម្រិតស្វ័យភាពរបស់គ្រូបង្រៀន។

## ៥.៤ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- បង្កើនគុណវុឌ្ឍិនិងបទពិសោធបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ដើម្បីបន្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

## ៥.៥ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

- ធ្វើទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់និងតាមគោលការណ៍
- លើកកម្ពស់ការគ្រប់គ្រងនិងរៀបចំក្របខ័ណ្ឌគ្រូបង្រៀន
- លើកកម្ពស់ដំណើរការនិងនីតិវិធីនៃការជ្រើសរើសនិងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អ សម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា
- ធ្វើប្រតិភូកម្មការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀននិងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធិសិក្សារបស់សិស្ស។

## ៥.៦ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ

- បណ្តុះវប្បធម៌រៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹងនិងបទពិសោធជាមួយបណ្តាញក្រុមអ្នកអប់រំ
- រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ
- រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការនិងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ។

## ៥.៧ លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារនិងរស់នៅរបស់គ្រូបង្រៀនតាមរយៈការផ្តល់បៀវត្សលាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្តជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក
- ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ
- លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។

## ៥.៨ ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន

- ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព
- ធានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ

- ធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើស បណ្តុះបណ្តាល បំពេញការងារ និងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេសនិងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ
- កំណត់និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃគ្រឹះស្ថានសិក្សាសាធារណៈ សំដៅធានាការអនុវត្តគោលការណ៍និងបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

## ៥.៩ ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន

- បង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន
- បង្កើតនិងប្រើប្រាស់យន្តការពិនិត្យតាមដាននិងវាយតម្លៃដើម្បីកែលម្អលទ្ធផលបំពេញការងាររបស់គ្រូបង្រៀន
- បង្កើនប្រសិទ្ធភាពការប្រើប្រាស់លទ្ធផលវាយតម្លៃការប្រតិបត្តិរបស់គ្រូបង្រៀនដើម្បីអភិវឌ្ឍសមិទ្ធិអប់រំ
- កំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចលើការគ្រប់គ្រងនិងអភិវឌ្ឍអង្គភាព។

# ៦. ផែនការសកម្មភាព

## ៦.១ ការបង្កើតយន្តការ

ពង្រឹងយន្តការដែលមានស្រាប់ ឬបង្កើតថ្មី ដើម្បីជំរុញការអនុវត្តការពិនិត្យតាមដាន ការវាយតម្លៃ និងការផ្តល់អនុសាសន៍កែលម្អការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន៖

- នៅថ្នាក់ជាតិ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកអនុវត្ត សម្របសម្រួល ពិនិត្យតាមដាន វាយតម្លៃ និងលើកសំណើកែលម្អការអនុវត្តគោលនយោបាយដោយសហការជិតស្និទ្ធជាមួយអង្គភាពស្ថាប័នពាក់ព័ន្ធ
- នៅថ្នាក់ក្រោមជាតិ ប្រធានអង្គភាព គ្រឹះស្ថានសិក្សា ជាអ្នកទទួលបន្ទុកសម្របសម្រួល ពិនិត្យតាមដាន វាយតម្លៃ និងអនុវត្តគោលនយោបាយ។

## ៦.២ ការបង្កើតក្របខណ្ឌគតិយុត្ត

- ប្រើរចនាសម្ព័ន្ធរដ្ឋបាលដែលមានស្រាប់ ក្នុងករណីចាំបាច់អាចបន្ថែមតួនាទីនិងភារកិច្ច ឬបង្កើតគណៈកម្មការថ្មី ដែលគណៈកម្មការនីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មការទាំងនេះត្រូវពិនិត្យឡើងវិញ កែសម្រួល ឬកសាងលិខិតបទដ្ឋានគតិយុត្តថ្មីចាំបាច់ ដើម្បីធានាការអនុវត្តដោយជោគជ័យនូវគោលនយោបាយស្តីពីគ្រូបង្រៀន រួមទាំងកសាងឯកសារសម្រាប់បំប៉ន ឬឧបករណ៍សម្រាប់ជាជំនួយដល់ការបណ្តុះបណ្តាល។

## ៦.៣ ការគាំទ្រហិរញ្ញវត្ថុ

ការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា និងថវិកាដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ៦.៤ ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន ត្រូវយកចិត្តទុកដាក់កសាងឯកសារសម្រាប់បំប៉ន ឬឧបករណ៍សម្រាប់ជាជំនួយដល់ការបណ្តុះបណ្តាល ការគ្រប់គ្រង និងការអភិវឌ្ឍគ្រូបង្រៀនឱ្យមានលក្ខណៈស្តង់ដារជាតិឆ្លើយតបទៅនឹងស្តង់ដារតំបន់និងស្តង់ដារសកលលោក។ ការបណ្តុះបណ្តាលធនធានមនុស្ស ត្រូវអនុវត្តតាមមុខសញ្ញានិងខ្លឹមសារដូចខាងក្រោម៖

- នាយកគ្រឹះស្ថានសិក្សាសាធារណៈ លើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការងារគ្រប់គ្រង ភាពជាអ្នកដឹកនាំ ការពិនិត្យតាមដាន វាយតម្លៃការប្រើប្រាស់ ការគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន
- គ្រូឧទ្ទេសនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន លើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងមុខវិជ្ជាឯកទេស សមត្ថភាពសម្របសម្រួល ការពិនិត្យតាមដាន និងវាយតម្លៃការបណ្តុះបណ្តាល ការអប់រំ និងការអភិវឌ្ឍគ្រូបង្រៀន
- មន្ត្រីផែនការអប់រំ លើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការរៀបចំផែនការ បុគ្គលិក ការវិភាគទិន្នន័យ តម្រូវការនិងការផ្គត់ផ្គង់គ្រូបង្រៀន
- មន្ត្រីអភិវឌ្ឍ ឬមន្ត្រីបណ្តុះបណ្តាលធនធានមនុស្ស លើខ្លឹមសារចំណេះដឹង ជំនាញ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន និងសមត្ថភាពទាក់ទងនឹងការវិភាគការងារ វិភាគតម្រូវការ ឬមុខសញ្ញាដែលត្រូវបណ្តុះបណ្តាលតាមតម្រូវការរបស់គ្រឹះស្ថានសិក្សាតាមលក្ខណៈជាប្រព័ន្ធ និងវិធីផ្តល់ការបណ្តុះបណ្តាល ឬអភិវឌ្ឍ
- គ្រូបង្រៀនទាំងអស់ លើខ្លឹមសារសមត្ថភាពវិជ្ជាជីវៈ ការស្រាវជ្រាវ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងថ្នាក់រៀន គរុកោសល្យ វិធីសាស្ត្របង្រៀន បច្ចេកទេសដែលទាក់ទងនឹងការងារគ្រូបង្រៀន និងចំណេះដឹងទាក់ទងនឹងគោលនយោបាយស្តីពីគ្រូបង្រៀន និងផលប្រយោជន៍ដែលទទួលបានពីការអនុវត្តគោលនយោបាយ។

## ៦.៥ ដំណើរការអនុវត្តគម្រោង

ដើម្បីធានាការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនឱ្យបានជោគជ័យ និងមានប្រសិទ្ធភាព ត្រូវយកចិត្តទុកដាក់លើ៖

- ការពិគ្រោះយោបល់ពីគ្រប់អ្នកពាក់ព័ន្ធលើការកសាងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនសំដៅធ្វើឱ្យមានសុខដុមនីយកម្មមូលនិធិទ្រទ្រង់សនិទានកម្មការគ្រប់គ្រងនិងការអភិវឌ្ឍគ្រូបង្រៀន ការអភិវឌ្ឍស្ថាប័ន ការអនុវត្តការងារវិមជ្ឈការនិងវិសហមជ្ឈការ និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ
- ភាពស៊ីសង្វាក់គ្នារវាងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនិងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ការពិនិត្យឡើងវិញ ការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្ត និងអនុសាសន៍កែលម្អគោលនយោបាយស្តីពីគ្រូបង្រៀន
- ការរៀបចំផែនការសកម្មភាពនិងផែនការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនសម្រាប់រយៈពេលខ្លីនិងមធ្យមៈ
    - ផ្សព្វផ្សាយឱ្យបានទូលាយតាមគ្រប់រូបភាពដល់គ្រប់អង្គភាព ឬស្ថាប័នអប់រំ និងអ្នកដែលពាក់ព័ន្ធនឹងគោលនយោបាយស្តីពីគ្រូបង្រៀន
    - រៀបចំការណែនាំលម្អិតសម្រាប់ការរៀបចំ ការកែលម្អ និងការកសាងថ្មីលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងគោលនយោបាយ
    - ធ្វើបច្ចុប្បន្នភាព សុក្រឹតកម្ម ទំនើបកម្មទិន្នន័យ ផែនការផ្គត់ផ្គង់និងតម្រូវការការបណ្តុះបណ្តាលគ្រូថ្មី និងផែនការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន
    - ធ្វើបច្ចុប្បន្នភាពតួនាទី និងភារកិច្ចសម្រាប់គ្រប់មុខតំណែងរបស់គ្រូបង្រៀន។

## ៧. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យគោលនយោបាយនេះមានវិសាលភាពអនុវត្តប្រកបដោយជោគជ័យស្របតាមបរិបទជាក់ស្តែង ចាំបាច់ត្រូវមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ វាយតម្លៃ ពិនិត្យឡើងវិញ និងសំណើកែលម្អនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលមានការចូលរួមពីគ្រប់អង្គភាព ឬស្ថាប័នដែលពាក់ព័ន្ធដោយផ្តោតលើៈ

- ចំណុចដៅនិងសូចនាករបណ្តុះបណ្តាល គ្រប់គ្រង និងអភិវឌ្ឍគ្រូបង្រៀននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការគោលសម្រាប់អភិវឌ្ឍគ្រូបង្រៀន
- ចំណុចដៅ និងយុទ្ធសាស្ត្រ ឬផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន
- លទ្ធផលដែលទទួលបានធៀបនឹងចំណុចដៅ និងស្តង់ដារដែលបានកំណត់
- ការចូលរួម ការទទួលផលប្រយោជន៍ និងផលប៉ះពាល់របស់អ្នកពាក់ព័ន្ធអប់រំទាំងអស់ក្នុងការអនុវត្តគោលនយោបាយនេះ
- ការធ្វើអធិការកិច្ច ឬសវនកម្មការបំពេញការងាររបស់មន្ត្រីគ្រប់គ្រងអប់រំ ទាក់ទងនឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន។

## ៨. សេចក្តីសន្និដ្ឋាន

គោលនយោបាយស្តីពីគ្រូបង្រៀនបានកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ ដែលជាទស្សនទានថ្មីសម្រាប់អភិវឌ្ឍគ្រូបង្រៀនឈានទៅរកការពង្រឹងគុណភាពនៃការបង្រៀននិងរៀនដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព។

ការទាក់ទាញ ការអភិវឌ្ឍសមត្ថភាព ការរក្សាទុក និងការធ្វើសនិទានកម្មគ្រូបង្រៀនឱ្យស្របតាមតម្រូវការគ្រឹះស្ថានសិក្សានៅគ្រប់រាជធានី ខេត្តទទួលបានលទ្ធផលល្អ គឺជាជោគជ័យក្នុងការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀន។ ប្រការនេះទាមទារឱ្យមានការរៀបចំផែនការសកម្មភាពច្បាស់លាស់ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ធនធានសម្ភារ និងការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមនិងជឿជាក់ថា គ្រូបង្រៀន ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍផ្នែកឯកជន សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមចំណែកក្នុងការជំរុញ ផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ។

# សទ្ទានុក្រម

**កម្មសិក្សាគរុកោសល្យ** សំដៅដល់ការហ្វឹកហាត់វិជ្ជាជីវៈក្នុងពេលបណ្តុះបណ្តាល។

**កម្មសិក្សា** សំដៅដល់ការហ្វឹកហាត់វិជ្ជាជីវៈក្រោយពេលបណ្តុះបណ្តាល។

**គុណវុឌ្ឍិ** សំដៅដល់លក្ខណសម្បត្តិលើសមត្ថភាពទទួលស្គាល់ជាផ្លូវការក្នុងក្របខណ្ឌអប់រំ ឬវិជ្ជាជីវៈ ដែលបញ្ជាក់ដោយសញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រ។

**គ្រឹះស្ថានបណ្តុះបណ្តាល** សំដៅដល់គ្រឹះស្ថានសិក្សាដែលទទួលបន្ទុកបណ្តុះបណ្តាលគ្រូបង្រៀន។

**ជំនាញ** សំដៅដល់លទ្ធផលនៃការរៀន បណ្តុះបណ្តាលនៅសាលា លទ្ធផលនៃបទពិសោធដែលទទួលបានពីការងារ លទ្ធផលនៃការប្រតិបត្តិ អនុវត្តចំណេះដឹង។

**សនិទានកម្ម** សំដៅដល់ការរៀបចំអង្គការចាត់តាំងរបស់អង្គភាពមួយទៅតាមគោលការណ៍វិទ្យាសាស្ត្រនៃការគ្រប់គ្រងដើម្បីបង្កើនប្រសិទ្ធភាព ការរៀបចំចាត់ចែងឡើងវិញរបស់អង្គភាពមួយដើម្បីបង្កើនប្រសិទ្ធភាព និងការរៀបចំឱ្យចម្រើនដោយចំណាយតិចបំផុត និងកាត់បន្ថយភាពខ្ជះខ្ជាយ។

**សមត្ថភាព** សំដៅដល់ចំណេះដឹង ជំនាញ សីលធម៌ដែលអាចធ្វើឱ្យមនុស្សម្នាក់ធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព ឬមុខងារដែលបានប្រគល់ជូនក្នុងកម្រិតស្តង់ដារដែលសង្ឃឹមទុក។

**ស្វ័យភាពរបស់គ្រូបង្រៀន** សំដៅដល់សមតុល្យរវាងស្វ័យអភិវឌ្ឍនិងឯករាជ្យភាពនៃវិជ្ជាជីវៈរបស់គ្រូបង្រៀន ដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលគ្រូបង្រៀនមានទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈ ឬការបង្រៀន និងកម្រិតសេរីភាពដែលគ្រូបង្រៀនមានអនុលោមតាមគោលនយោបាយ។